អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មានស្តីពីកិច្ចប្រជុំពេញអង្គ

កិច្ចប្រជុំពេញអង្គលើកក្រោយរបស់មន្ត្រីតុលាការនៃ អ.វ.ត.ក នឹងប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២៨ ខែមករា ដល់ ថ្ងៃទី០១ កុម្ភៈ ឆ្នាំ២០០៨។ កិច្ចប្រជុំពេញអង្គនឹងចាប់ផ្តើមនៅថ្ងៃទី២៨ ខែមករា ដោយមួយព្រឹកសម្រាប់ត្រៀមរៀបចំ ហើយពិធីបើកជាផ្លូវការនឹងប្រព្រឹត្តទៅនៅថ្ងៃដដែលនោះ វេលាម៉ោង ១៣:៣០។

កិច្ចប្រជុំពេញអង្គគឺជាកិច្ចប្រជុំអសាធរណៈ ប៉ុន្តែប្រព័ន្ធផ្សព្វផ្សាយត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកម្មវិធីបើកកិច្ចប្រជុំពេញអង្គនៅថ្ងៃច័ន្ទ ទី២៨ ខែមករា ឆ្នាំ២០០៨ នៅវេលាម៉ោង ១៣:៣០។ ឱកាសថតរូបជាផ្លូវការនឹងត្រូវបានផ្តល់ជូនក្នុងកិច្ចប្រជុំនេះ ដែលនឹងរៀបចំឡើងនៅសណ្ឋាគារ Raffles Hotel Le Royal។

នៅពេលបញ្ចប់កិច្ចប្រជុំពេញអង្គ សេចក្តីថ្លែងការណ៍សង្ខេបនឹងចេញផ្សាយដោយផ្នែកកិច្ចការសាធារណៈ ដល់សារព័ត៌មានទាំងអស់ដែលចាប់អារម្មណ៍។

យើងខ្ញុំសូមសំណូមពរដល់តំណាងប្រព័ន្ធផ្សព្វផ្សាយទាំងនោះដែលចាប់អារម្មណ៍ចូលរួមកម្មវិធីផ្តិតយករូបភាព សូមមេត្តាទាក់ទងមន្ត្រីសារព័ត៌មាន អ.វ.ត.ក លោក រាជ សម្បត្តិ តាមរយៈទូរស័ព្ទលេខ ០១២ ៤៨៨ ១៥៦ ឬ តាមអ៊ីមែល៖ reach.sambath@eccc.gov.kh។

សូមបញ្ជាក់ថា លោក-លោកស្រី តម្រូវឲ្យមានអត្តសញ្ញាណត្រឹមត្រូវទើបអាចចូលរួមព្រឹត្តិការណ៍នៅ អ.វ.ត.ក ដើម្បីផ្តិតយករូបភាពសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ។

Original EN: 01699273-01699273